mith samlanh

# អង្គការមិត្តសំឡាញ់
# កម្មវិធីអបអរសាទរទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍
# ថ្ងៃអង្គារ ទី០១ ខែ ធ្នូ ឆ្នាំ ២០១៥

ក៏ដូចជារៀងរាល់ឆ្នាំ អង្គការមិត្តសំឡាញ់បានប្រារព្ធ ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃ ទី០១ ខែ ធ្នូ ឆ្នាំ ២០១៥ ក្រោមប្រធានបទ «ឈានទៅរក គ្មានការរើសអើង គ្មានការឆ្លងថ្មី គ្មានការស្លាប់» ដើម្បីចូលរួមកាត់បន្ថយ ការឆ្លងរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ ក្នុងចំណោមប្រជាជនកម្ពុជាសំដៅឆ្លើយតបទៅនឹងយុទ្ធសាស្រ្ត សូម្បីរបស់រាជរដ្ឋាភិបាលកម្ពុជា។

ព្រឹត្តការណ៍នេះរៀបចំដោយ កុមារ/យុវវ័យ មិត្តអប់រំមិត្ត របស់អង្គការមិត្តសំឡាញ់ ដោយមានការគាំទ្រពីបុគ្គលិក និងមានការចូលរួមពី កុមារ/យុវវ័យ មកពីតាមថ្នល់ សហគមន៍ អង្គការដៃគូនានាតំណាងភ្នាក់ងាររដ្ឋាភិបាល ម្ចាស់ជំនួយ និងអាជ្ញាធរដែនដី ដែលមានអ្នកចូលរួមសរុបប្រមាណ ៨៥០នាក់។

បន្ថែមលើការ អប់រំផ្សព្វផ្សាយអំពី មេរោគអេដស៍ ជម្ងឺអេដស៍ និងដើម្បីញ៉ាំងកម្មវិធីនេះឲ្យកាន់តែមានភាពសប្បាយរីករាយ និងទាក់ទាញខ្លាំង នៅក្នុងព្រឹត្តកាណ៍នេះមានសកម្មភាពកំសាន្តមួយចំនួនត្រូវបានរៀបចំចាប់ពីម៉ោង២.00 ដល់ម៉ោង ៤.00នាទីៈ មានដូចជាកម្មវិធីសិល្បៈនិងសំនួរចម្លើយ ល្បែងកំសាន្ត រាំកំសាន្ត នៅអង្គការមិត្តសំឡាញ់ ផ្ទះលេខ ២១៥ ផ្លូវ១៣ សង្កាត់ ជ័យជំនះ ខណ្ឌ ដូនពេញ ។

យើងខ្ញុំសង្ឃឹមថាតាមរយះព្រឹត្តិការណ៍នេះប្រជាជន យុវវ័យកម្ពុជាកាន់តែយល់ដឹងច្បាស់នឹងចូលរួមសំរេចយុទ្ធសាស្រ្ត សូន្យបី ២០១១-២០២០ គ្មានការរើសអើង គ្មានការឆ្លងថ្មី គ្មានការស្លាប់ ដោយមេរោគអេដស៍/ជំងឺអេដស៍ និងសូមឲ្យទាំងអស់គ្នា អញ្ជើញចូលរួមគ្រប់ៗគ្នាពិសេសស្នើសុំប្រព័ន្ធផ្សព្វផ្សាយនានា អញ្ជើញមកយកព័ត៌មានដើម្បីចាក់ផ្សាយកម្មវិធីនេះសំរាប់សាធារណៈជនទូទៅ ។

កម្មវិធីនេះអាចដំណើការទៅបានដោយមានការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយ DCA/CA, និង
ឧបត្ថម្ភ បច្ចេកទេសពីអង្គការ Friends-International ៕

សូមអរគុណ!